**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ..២៣៤...សស.ឃស/ខ្ងក

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ២០១១...

# រដ្ឋមន្ត្រីក្រសួងសុខាភិបាល

ជម្រាបមក

## លោក - លោកស្រី នាយកមន្ទីរសុខាភិបាលរាជធានី-ខេត្ត

**កម្មវត្ថុ:** វគ្គបណ្ដុះបណ្ដាលអេពីដេមីសាស្ត្រអនុវត្តឆ្នាំ២០១២ រយៈពេល៦ខែ សម្រាប់មន្ត្រីនៃមន្ទីរសុខាភិបាល ស្រុកប្រតិបត្តិ រាជធានី-ខេត្ត ដែលបំពេញការងារទាក់ទងនឹងប្រព័ន្ធតាមដានជំងឺឆ្លង។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបលោក លោកស្រីនាយកថា នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងរួមសហការនឹងអង្គការសុខភាពពិភពលោកប្រចាំនៅកម្ពុជា នឹងរៀបចំវគ្គបណ្ដុះបណ្ដាលអេពីដេមីសាស្ត្រអនុវត្តជំនាន់ទីពីរ រយៈពេលប្រាំមួយខែ សម្រាប់ឆ្នាំ២០១២ ខាងមុខនេះ។ វគ្គនេះមានគោលបំណងអភិវឌ្ឍចំណេះដឹង ជំនាញ សមស្រប និងពង្រឹងសមត្ថភាពមន្ត្រីនៃមន្ទីរសុខាភិបាល ស្រុកប្រតិបត្តិ រាជធានី - ខេត្ត ដែលបំពេញការងារទាក់ទងនឹងប្រព័ន្ធតាមដានជំងឺក្នុងតំបន់ទទួលខុសត្រូវរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងការផ្ទុះ ការរាតត្បាតជំងឺ។ ក្នុងរយៈពេលសិក្សា សិក្ខាកាមត្រូវចំណាយរយៈពេលពី ៨ ទៅ ១០ សប្ដាហ៍ ដើម្បីសិក្សាទ្រឹស្ដីនៅនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល និងត្រលប់ទៅបំពេញការងារនៅកន្លែងដើមវិញ ដើម្បីអនុវត្តការតាមដាន និងឆ្លើយតបទៅនឹងការរាតត្បាត ដោយមានកិច្ចអភិបាលពីសំណាក់អ្នកអភិបាលជាតិ និងអន្តរជាតិ។ ក្រោយពីបញ្ចប់ការបណ្ដុះបណ្ដាលមន្ត្រីទាំងនោះ ត្រូវត្រលប់ទៅបម្រើការងារនៅអង្គភាពដើមវិញឱ្យបានយ៉ាងតិចរយៈពេលមួយឆ្នាំ ដើម្បីរួមចំណែកធ្វើឱ្យប្រសើរឡើងការតាមដាន និងឆ្លើយតបទៅនឹងការរាតត្បាត។

ការទទួលពាក្យសុំចូលរៀននឹងចាប់ផ្ដើមពីថ្ងៃផ្សព្វផ្សាយនេះ រហូតដល់ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១១។ សិក្ខាកាម៥នាក់ នឹងត្រូវបានជ្រើសរើសក្នុងចំណោមបេក្ខជនដែលបានដាក់ពាក្យ សម្រាប់ជំនាន់ទីពីរ នេះ។ រាល់ការចំណាយក្នុងការបណ្ដុះបណ្ដាលជាបន្ទុករបស់អង្គការសុខភាពពិភពលោក។ អាស្រ័យហេតុនេះ សូមលោក លោកស្រីនាយកជួយផ្សព្វផ្សាយ និងលើកទឹកចិត្តមន្ត្រីក្រោមឱវាទដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឱ្យដាក់ពាក្យសុំចូលរៀនក្នុងវគ្គនេះកុំបីអាក់ខានឡើយ។

សូមលោក លោកស្រីនាយកទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

ពាក្យសុំចូលរៀន និងព័ត៌មានផ្សេងៗសូមបើកមើល website របស់នាយកនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង (www.cdcmoh.gov.kh)។

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

សាស្ត្រាចារ្យ **អេង_ហួត**

# វគ្គបណ្តុះបណ្តាលអេពីដេមីសាស្ត្រអនុវត្តនៅកម្ពុជា

# ក្រសួងសុខាភិបាល

នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល សហការជាមួយអង្គការសុខភាពពិភពលោក នឹងរៀបចំវគ្គបណ្តុះបណ្តាលអេពីដេមីសាស្ត្រអនុវត្ត ស្តីពីការតាមដាននិងឆ្លើយតបការផ្ទុះរោគរាតត្បាតជំនាន់ទីពីរ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី៣០ខែមករា ដល់ ថ្ងៃទី៣ខែសីហា ឆ្នាំ ២០១២។ វគ្គបណ្តុះបណ្តាលនេះ មានគោលបំនងផ្តល់អោយសិក្ខាកាមនូវចំណេះដឹង និងជំនាញសមស្របព្រមទាំងឱកាសដើម្បីអភិវឌ្ឍសមត្ថភាពក្នុងការអនុវត្តការតាមដាន និង ឆ្លើយតបទៅនឹងការផ្ទុះការរាតត្បាតអោយមានប្រសិទ្ធភាពនៅក្នុងប្រទេសកម្ពុជា។

វគ្គបណ្តុះបណ្តាលនេះ នឹងគ្របដណ្តប់ទៅលើមុខវិជ្ជាដូចតទៅ:

- បច្ចេកទេសអេពីដេមីសាស្ត្រ
- ជីវស្ថិតិវិទ្យា
- ការតាមដានសុខភាពសាធារណ:
- ទីពិសោធន៍ និង ជីវសុវត្ថិភាព
- ការប្រាស្រ័យទាក់ទង
- បច្ចេកទេសពតិមានវិទ្យា ការប្រើប្រាស់កំព្យូទ័រ អ៊ិនធឺណែត និង កម្មវិធីវិភាគពតិមាន
- ការបង្ការនិងទប់ស្កាត់ជំងឺជាអាទិភាព

សិក្ខាកាមក្នុងវគ្គសិក្សានេះ នឹងទទួលបានឱកាសសិក្សាបន្ថែមភាសាអង់គ្លេសវគ្គពិសេសមួយដែលរៀបចំជូនដោយកម្មវិធីដើម្បីលើកកម្ពស់សមត្ថភាពយល់ដឹងផ្នែកភាសាអង់គ្លេសរបស់សិក្ខាកាមអោយកាន់តែមានប្រសិទ្ធភាព។ ក្នុងរយៈពេលប្រាំមួយខែនៃការបណ្តុះបណ្តាលនេះ សិក្ខាកាមនឹងត្រូវស្នាក់នៅក្នុងរាជធានីភ្នំពេញរយៈពេលពី ៨ ទៅ ១០ សប្តាហ៍សិក្សាទ្រឹស្តី និងអនុវត្តជាក់ស្តែងរយៈពេលបួនខែទៀតនៅតាមកន្លែងការងារដើមរបស់ខ្លួន អំពីការតាមដាន និង សកម្មភាពស្រាវជ្រាវការផ្ទុះការរាតត្បាតជំងឺក្រោមអភិបាលកិច្ចពីសំណាក់អ្នកអភិបាលថ្នាក់ជាតិ និងអន្តរជាតិ។

សិក្ខាកាមនឹងទទួលបានការឧបត្ថម្ភការចំណាយប្រចាំខែក្នុងកំឡុងពេលសិក្សា។ រាល់សោហ៊ុយចំណាយលើការសិក្សាជាបន្ទុករបស់កម្មវិធីបណ្តុះបណ្តាល។ ក្រោយពីបញ្ចប់ការសិក្សានេះទៅ សិក្ខាកាមនឹងតម្រូវអោយវិលត្រឡប់ទៅបំរើការងារនៅកន្លែងដើមវិញអោយបានយ៉ាងតិចរយៈពេលមួយឆ្នាំ។

បុគ្គលិកក្របខ័ណ្ឌរបស់ក្រសួងសុខាភិបាលទាំងឡាយដែលបំពេញលក្ខខ័ណ្ឌតម្រូវដូចខាងក្រោម ត្រូវបានលើកទឹកចិត្តអោយដាក់ពាក្យសុំចូលសិក្សាវគ្គបណ្តុះបណ្តាលនេះ

១-កំពុងបម្រើការងារជាសមាជិកក្រុមឆ្លើយតបបន្ទាន់នៅថ្នាក់ខេត្ត ឬ រាជធានី ឬ ស្រុកប្រតិបត្តិ មានរយៈពេលយ៉ាងតិចបានមួយឆ្នាំគិតមកដល់ថ្ងៃដាក់ពាក្យ។

២-កំពុងបម្រើការងារទាក់ទងនឹងប្រព័ន្ធតាមដានជំងឺនៅថ្នាក់ខេត្ត ឬ រាជធានី ឬ ស្រុកប្រតិបត្តិមានរយៈពេលយ៉ាងតិចបានមួយឆ្នាំគិតមកដល់ថ្ងៃដាក់ពាក្យ។

៣- ជាវេជ្ជបណ្ឌិត គ្រូពេទ្យមធ្យម ឱសថការី ទន្តបណ្ឌិត ទន្តពេទ្យមធ្យម ឬគិលានុប្បដ្ឋាក-យិកា។

៤-មានចំណេះដឹងផ្នែកភាសាអង់គ្លេសបង្គួរ (អាចអាន និយាយ និងសរសេរខ្លះៗ)

៥-មានបទពិសោធន៏ក្នុងការប្រើប្រាស់កំព្យូទ័រ (World, Excel, Powerpoint)

បើអស់លោក លោកស្រីមានចំណាប់អារម្មណ៏ សូមមេត្តាបំពេញបែបបទ និងឯកសារតម្រូវផ្សេងៗ យកមកដាក់នៅផ្នែកបណ្តុះបណ្តាលអេពីដេមីសាស្ត្រអនុវត្ត (AET Office) នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង បន្ទប់ជាន់ទីបួនអាគារថ្មីនៃក្រសួងសុខាភិបាល ឬដាក់ជូនលោកវេជ្ជបណ្ឌិត **សុខ ទូច** ប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង **(CDC)** ដោយផ្ទាល់ ឬ តាមរយៈអ៊ីម៉ែល touch358@moh.gov.kh និង ចម្លងជូន (CC) មក អ៊ីម៉ែល aetcambodia@gmail.com។ ការដាក់ពាក្យនេះត្រូវធ្វើអោយបានមុនថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១១។ ប្រសិនបើមានចម្ងល់ អស់លោក លោកស្រី អាចទំនាក់ទំនងមកលោក វេជ្ជបណ្ឌិត ហាស់ ផលមុនី ទូរស័ព្ទ: ០១១ ៩២៣ ៧៤២ អ៊ីម៉ែល: hasp@wpro.who.int **ឬ** លោកវេជ្ជបណ្ឌិត ប៊ុន ស្រេង ទូរស័ព្ទ: ០១២ ៨៥២ ៨២៤ អ៊ីម៉ែល: bun_sreng72@yahoo.com

បេក្ខជនដែលបានជាប់ជម្រើសក្នុងបញ្ជី នឹង ត្រូវបានអញ្ជើញអោយមកធ្វើសម្ភាសន៏។